**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៥៥៦ ព.ណ.កសប

ថ្ងៃសុក្រ ១២កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០២៥

## ជម្រាបមក
## លោក/លោកស្រី ប្រធានក្រុមហ៊ុន អេ & អេ អូតូ គ្រុប

**កម្មវត្ថុ៖** ករណីស្នើសុំការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្តពាក់ម៉ាក KIA ។

**យោង** ៖-ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-ប្រកាសលេខ ០១១៧ ព.ណ កសប ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

-លិខិតស្នើសុំរបស់ **ក្រុមហ៊ុន អេ & អេ អូតូ គ្រុប** ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ ២០២៥

-លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Kia Corporation ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២៥

-លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Kia Asia Pacific Sdn. Bhd. ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ ២០២៥

**ជូនភ្ជាប់៖** បញ្ជីម៉ូដែល ម៉ាក KIA

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក/លោកស្រីប្រធានក្រុមហ៊ុនជ្រាបថា យោងតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា៣ និងមាត្រា១១ និងយោងតាមប្រកាស ស្តីពី នីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ដែលប្រការ៨ចែងថា ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក អ្នកស្នើសុំត្រូវចុះបញ្ជីម៉ាក នៅក្រសួងពាណិជ្ជកម្ម។

ក្នុងករណីដែលក្រុមហ៊ុនបានចុះបញ្ជីម៉ាក KIA អាចធ្វើការស្នើសុំកត់ត្រាទទួលស្គាល់សិទ្ធិនាំចូលនិងចែកចាយផ្តាច់មុខចំពោះតែម៉ាកនោះប៉ុណ្ណោះ។ ចំពោះប្រភេទរថយន្តដែលមានម៉ាកនៃម៉ូដែលជាច់ដោយឡែកជ្រកក្រោមម៉ាកខាងលើ ដូចជា ម៉ាក Picanto, Morning, Ray, Ray EV, Stonic, Carens, Seltos, Syros, Sonnet, Soul, Sportage ។ល។ ត្រូវធ្វើការចុះបញ្ជីម៉ាកនៃម៉ូដែលនោះជាមុនសិន ក្នុងករណីដែលត្រូវស្នើសុំកត់ត្រាសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ចំពោះម៉ាកនៃម៉ូដែលនីមួយៗ នៅក្រសួងពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុនជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាព។

សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

# បញ្ជីម៉ូដែលភ្ជាប់ ម៉ាក KIA

| ល.រ | ឈ្មោះ ម៉ូដែល |
|---|---|
| 1 | Picanto |
| 2 | Morning |
| 3 | Ray |
| 4 | Ray EV |
| 5 | Stonic |
| 6 | Carens |
| 7 | Seltos |
| 8 | Syros |
| 9 | Sonnet |
| 10 | Soul |
| 11 | Sportage |
| 12 | Sportage Hybrid |
| 13 | Sportage Plug in Hybrid |
| 14 | Sorento |
| 15 | Sorento Hybrid |
| 16 | Sorento Plug in Hybrid |
| 17 | Carnival |
| 18 | Carnival Hybrid |
| 19 | Carnival Hi Limousine |
| 20 | Telluride |
| 21 | Tasman |
| 22 | Cerato |
| 23 | Forte |
| 24 | K3 |
| 25 | K4 |
| 26 | K5 |
| 27 | K7 |
| 28 | K8 |
| 29 | K9 |
| 30 | Niro |
| 31 | Niro Hybrid |
| 32 | Niro Plug in Hybrid |
| 33 | Niro EV |
| 34 | EV3 |
| 35 | EV5 |
| 36 | EV6 |
| 37 | EV6 GT |
| 38 | EV9 |
| 39 | Bongo III |
| 40 | Bongo III EV |
| 41 | Granbird |